# ការឃ្លាំមើលសវនាការ



**សាលាដំបូងរាជធានី-ខេត្ត ( ០១ តុលា ២០២៣ - ៣០ កញ្ញា ២០២៤ )**

**ភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៤**

Address: #3, St 158 Ouknha Trorung Kang, Boeng Raing, Daun Penh, Phnom Penh
Tel: (+855-23) 218 553/210 518/990 544
P.O Box: 1024 – P.O Box 20 at CCC
E-mail: info@adhoccambodia.org
Website: www.adhoccambodia.org
Facebook: www.facebook.com/adhoccam
Twitter: www.twitter.com/adhoccam

# មាតិកា

I. សេចក្តីផ្តើម ........ 3
II. ព័ត៌មានទូទៅ និងភាគីក្នុងរឿងក្តី ........ 4
III. សិទ្ធិក្នុងពេលជំនុំជម្រះ ........ 5
IV ការប្រតិបត្តិរបស់មេធាវី ........ 8
V. អនុសាសន៍ ........ 12

## I. សេចក្តីផ្តើម

**អំពីសមាគមអាដហុក៖** សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា "សមាគមអាដហុក" ជាអង្គការក្រៅរដ្ឋាភិបាលមួយ ឯករាជ្យ អព្យាក្រឹត មិនរកផលចំណេញ និងមិនស្ថិតក្រោម ការឃុំគ្រងរបស់គណបក្សនយោបាយណាមួយឡើយ ។ សមាគមអាដហុក ជាអង្គការសិទ្ធិមនុស្សដំបូងគេដែលត្រូវបានបង្កើតឡើង នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩១ នឹងត្រូវបានទទួលស្គាល់ជាផ្លូវការដោយសម្តេចព្រះ នរោត្តម សីហនុ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩២ ព្រមទាំងចុះបញ្ជីក្រសួងមហាផ្ទៃ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ ប្រកាសលេខ២៧៨ ។

សមាគមអាដហុក ធ្វើសកម្មភាពមានវិសាលភាពទូទាំងប្រទេស ដែលមានស្នាក់ការកណ្តាល នៅរាជធានីភ្នំពេញ ព្រមទាំងមានស្នាក់ការសាខានៅតាមបណ្តាខេត្តគោលដៅចំនួន២១មាន៖ ១-ខេត្តព្រៃវែង ២-ខេត្តកំពង់ចាម ៣-ខេត្តក្រចេះ ៤-ខេត្តស្ទឹងត្រែង ៥-ខេត្តរតនគីរី ៦-ខេត្តមណ្ឌលគីរី ៧-ខេត្តកំពត ៨-ខេត្តកោះកុង ៩-ខេត្តព្រះសីហនុ ១០-ខេត្តកំពង់ធំ ១១-ខេត្តកំពង់ឆ្នាំង ១២-ខេត្តបាត់ដំបង ១៣-ខេត្តបន្ទាយមានជ័យ ១៤-ខេត្តឧត្តរមានជ័យ ១៥-ខេត្តសៀមរាប ១៦-ខេត្តព្រះវិហារ ១៧-ខេត្តកំពង់ស្ពឺ ១៨-ខេត្តពោធិ៍សាត់ ១៩-ខេត្តប៉ៃលិន ២០-ខេត្តស្វាយរៀង និង២១-ខេត្តត្បូងឃ្មុំ ។

សមាគមអាដហុក បានធ្វើការងារដើម្បីចូលរួម គោរព-ការពារ-លើកកម្ពស់ សិទ្ធិមនុស្សជាមូលដ្ឋាន សេរីភាពជាមូលដ្ឋាន និងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់ជូនប្រជាពលរដ្ឋនូវចំណេះដឹង និងការយល់ដឹងអំពីសិទ្ធិមនុស្ស ច្បាប់ លទ្ធិប្រជាធិបតេយ្យ របៀបការពារសិទ្ធិ និងសេរីភាពរបស់ខ្លួន ព្រមទាំងឃ្លាំមើល អន្តរាគមន៍ការរំលោភសិទ្ធិមនុស្ស ផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ និងផ្តល់សេវាផ្នែកច្បាប់ដោយមិនគិតកម្រៃ។ គោលបំណងចម្បង របស់សមាគមអាដហុក គឺជួយជនរងគ្រោះពីការរំលោភបំពាន អាចមានសមត្ថភាពស្វែងរកយុត្តិធម៌ដោយខ្លួនឯង ពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងលើកទឹកចិត្តប្រជាពលរដ្ឋអាចចូលរួមធ្វើការតស៊ូមតិលើកកម្ពស់ និងការកែលម្អច្បាប់ ស្ថាប័ននានា និងការអនុវត្តច្បាប់ឲ្យប្រសើរឡើង ដោយសន្តិវិធី។

**វិធីសាស្ត្រ៖** របាយការណ៍ "ការឃ្លាំមើលសវនាការជំនុំជម្រះ" ត្រូវបានរៀបចំចងក្រងឡើងដោយបានប្រមូលព័ត៌មានតាមរយៈ របាយការណ៍ឃ្លាំមើលសវនាការ របស់មន្ត្រីបុគ្គលិក អ្នកសម្របសម្រួល ការិយាល័យសមាគមអាដហុក នៅតាមបណ្តាខេត្ត/រាជធានីមានវិសាលភាពអនុវត្តសកម្មភាពទូទាំងប្រទេស ដែលបានចូលរួមក្នុងសវនាការជំនុំជម្រះដោយផ្ទាល់។ ករណីទាំងអស់ដែលបុគ្គលិកសមាគមអាដហុក បានចូលរួមក្នុងសវនាការជំនុំជម្រះដោយផ្ទាល់ គឺជាករណីដែលស្ថិតនៅក្នុងអាណត្តិរបស់សាមាគម ហើយជាករណីដែលសមាគមអាដហុកបានផ្តល់សេវាផ្នែកច្បាប់(ផ្តល់មេធាវី) ដើម្បីតំណាងដោយអាណត្តិ ការពារតាមផ្លូវច្បាប់តាមសំណើជនរងគ្រោះផ្ទាល់។ ទម្រង់ឃ្លាំមើលសវនាការមាន១៩សំនួរ ត្រូវបានបង្កើតឡើងសំរាប់ប្រើប្រាស់កត់ត្រា ព្រឹត្តិការណ៍បានកើតឡើងអំឡុងពេលនីតិវិធី-ពេលចូលរួមឃ្លាំមើលសវនាការជំនុំជម្រះ ហើយបញ្ជូនរបាយការណ៍នោះ មកស្នាក់ការកណ្តាលភ្នំពេញបញ្ចូលក្នុងទិន្នន័យដែលបានបង្កើត (កញ្ចប់ស្ថិតិវិទ្យាសាស្ត្រសង្គម 'SPSS') ដើម្បីប្រើប្រាស់ក្នុងការធ្វើវិភាគ និងសរសេរចងក្រងជារបាយការណ៍។

**គោលបំណង៖** របាយការណ៍" ការឃ្លាំមើលសវនាការជំនុំជម្រះ " ត្រូវបានធ្វើឡើង ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់សិទ្ធិស្វែងរកយុត្តិធម៌ប្រកបដោយតម្លាភាព និងធានាភាពគ្មានអគតិទាំងបួន ជាពិសេសចូល

រួមក្នុងការផ្តល់ព័ត៌មានដែលបានរកឃើញពាក់ព័ន្ធ ការប្រតិបត្តិវិស័យយុត្តិធម៌របស់ចៅក្រមតំណាងអយ្យការ និងមេធាវីក្នុងគោលបំណង ធ្វើឲ្យកាន់តែប្រសើរឡើងប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជា។

## II. ព័ត៌មានទូទៅ និងនាតីក្នុងរឿងក្តី

របាយការណ៍ " **ការឃ្លាំមើលសវនាការជំនុំជម្រះ** " ធ្វើឡើងក្នុងវិសាលភាពត្រឹមកម្រិតអង្គជំនុំជម្រះសាលាដំបូងរាជធានី-ខេត្ត "តុលាការខេត្ត-រាជធានី" ដែលបានចូលរួមឃ្លាំមើលសវនាការ ចាប់ពីខែតុលា ឆ្នាំ២០២៣ ដល់ខែកញ្ញា ឆ្នាំ២០២៤។

អំឡុងពេលរបាយការណ៍បុគ្គលិកសមាគមអាដហុក បានចូលរួមឃ្លាំមើលសវនាការជំនុំជម្រះ៧៧ករណីនៅតាមបណ្តាសាលាដំបូងរាជធានី-ខេត្តចំនួន១៧ ដែលមានមេធាវីតំណាងឲ្យសមាគមអាដហុកជាអ្នកតំណាងដោយអាណត្តិផ្លូវច្បាប់ដល់ជនរងគ្រោះផ្ទាល់ ដូចជាសាលាដំបូង៖ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តមណ្ឌលគិរី ខេត្តព្រៃវែង ខេត្តពាធិសាត់ ខេត្តរតនៈគិរី ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តបាត់ដំបង ខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តកោះកុង។

៧៧ករណី ដែលសមាគមអាដហុក បានចូលរួមឃ្លាំមើលសវនាការ និងផ្តល់មេធាវីការពារផ្លូវច្បាប់នោះ មាន **២៩(៣៨%)ករណី ទាក់ទងការរំលោភសិទ្ធិមនុស្សទូទៅ ១៦(២១%)ករណីរំលោភសិទ្ធិដីធ្លី** និង**៣២(៤១%)ករណីរំលោភសិទ្ធិស្ត្រី និងកុមារ**។ ដែលក្នុងនោះរួមមាន ករណីគម្រាមកំហែងសកម្មជននយោបាយច្រើនជាគេគឺ៥០ករណី ករណីគម្រាមកំហែងសកម្មជនសិទ្ធិមនុស្ស ករណីរំលោភយកដីដោយអ្នកមានអំណាច និងករណីការចាប់ខ្លួនខុសច្បាប់។

៧៧ករណី ដែលសមាគមអាដហុក បានចូលរួមឃ្លាំមើលសវនាការ និងផ្តល់មេធាវីការពារផ្លូវច្បាប់នោះ មានករណីកម្រិតទោស បទឧក្រិដ្ឋចំនួនករណី៤០ និងបទមជ្ឈិមចំនួន៣៧ករណី(បទលហុគ្មាន) មានជនជាប់ចោទ/ចុងចម្លើយជាជនរងគ្រោះសរុបចំនួន៣២៨នាក់ (ស្ត្រីចំនួន៧៨នាក់ កុមារចំនួន១៤នាក់ ហើយក្នុងនោះអវត្តមានក្នុងពេលសវនាការចំនួន៦៣នាក់) និងដើមបណ្តឹងជាជនរងគ្រោះសរុបចំនួន១០៦នាក់ (ស្ត្រីចំនួន៤២នាក់ កុមារចំនួន០៧នាក់ ហើយក្នុងនោះអវត្តមានក្នុងពេលសវនាការចំនួន១១នាក់)។

**ការលើកពេលសវនាការ៖** ក្នុងចំណោម៧៧ករណី មាន៣៨ករណីជំនុំជម្រះដោយចៅក្រមទោល និង៣៩ករណីដោយចៅក្រមក្រុមប្រឹក្សា។ ក្នុងនោះតុលាការ បានលើកពេលសវនាការជំនុំជម្រះចំនួន១៣(១៧%) ក្រោមមូលហេតុសមាសភាពចៅក្រមក្រុមប្រឹក្សាជាប់រវល់-មានជម្ងឺ អវត្តមានសាក្សី គ្មានចម្លើយជនត្រូវចោទនៅតំណាក់កាលចៅក្រមស៊ើប និងតុលាការត្រូវការភស្តុតាងបន្ថែម។

**ការឃុំខ្លួនបណ្តោះអាសន្នលើ៦ខែ** [1] **៖** ក្នុងចំណោម៧៧ករណី មាន៤២ករណី ដែលជនជាប់ចោទត្រូវបានតុលាការសំរេចឃុំខ្លួនបណ្តោះអាសន្ន។ យោងតាមរបាយការណ៍បានបង្ហាញថា បើគិតមកដល់ថ្ងៃបើកសវនាការ ការឃុំខ្លួនបណ្តោះអាសន្នលើសថេរវេលាច្បាប់បានកំណត់ នៅតែបន្តកើតមាន នៅតាមតុលាការរាជ

[1] មាត្រា២០៨ មាត្រា២០៩ មាត្រា២៤៩ មាត្រា២៨៣ និងមាត្រា៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ធានី-ខេត្ត ដែលមានចំនួន៤២(៥៤.៦%) ក្នុងចំណោម៧៧ករណី បើធៀបរបាយការណ៍ចុងឆ្នាំ២០២៣ មាន៨០(៤៥.៧១%)ក្នុងចំណោម១៧៥ករណី **បង្ហាញការកើនឡើងជាងឆ្នាំមុនចំនួន៨.៨៩%៖**

| **មករា២០២២ - កក្កដា២០២៣ (១៧៥ករណី)** | | **តុលា២០២៣ - កញ្ញា២០២៤ (៧៧ករណី)** | |
|---|---|---|---|
| ចំនួនខែឃុំខ្លួនលើសនីតិវិធី | ករណី(៨០) | ចំនួនខែឃុំខ្លួនលើសនីតិវិធី | ករណី(៤២) |
| ចន្លោះលើសពី៦ខែ - ៩ខែ | ៣៤ | ចន្លោះលើសពី៦ខែ - ៩ខែ | ២២ |
| ចន្លោះលើសពី១០ខែ - ១២ខែ | ១២ | ចន្លោះលើសពី១០ខែ - ១២ខែ | ០៣ |
| ចន្លោះលើសពី១៨ខែ - ២៣ខែ | ០២ | លើសពី១៨ខែ | ០២ |
| ចន្លោះលើសពី២៤ខែឡើង | ៣២ | ចន្លោះលើសពី៣ខែ - ៦ខែ | ១៥ |

**ភាពខុសគ្នារវាងពេលវេលាបានកំណត់ក្នុងដីកា និងពេលវេលាបើសវនាការជំនុំជម្រះជាក់ស្តែង៖** យោងតាមរបាយការណ៍ក៏បានបង្ហាញឲ្យឃើញថាៈ តុលាការរាជធានី-ខេត្ត ជាពិសេសចៅក្រមសវនាការជំនុំជម្រះ **នៅ** *តែបន្តភាពយឺតយ៉ាវ ក្នុងការបើកសវនាការជំនុំជម្រះជាក់ស្តែង បើធៀបនឹងម៉ោងដែលបានកំណត់នៅក្នុងដីកាកោះ/ដីកាអញ្ជើញ* រហូតដល់ចន្លោះពីមួយម៉ោងកន្លះ ដល់ ពីរម៉ោង (បើម៉ោងក្នុងដីកាកំណត់ថាសវនាការជំនុំជម្រះចាប់ផ្តើមនៅម៉ោង០៨:០០ព្រឹកជាកំហិត...ប៉ុន្តែម៉ោងដែល នឹងចាប់ផ្តើមសវនាការជំនុំជម្រះជាក់ស្តែងអាចចាប់ផ្តើមម៉ោង០៩:៣០នាទី ឬពេលខ្លះអាចយឺតរហូតដល់ ម៉ោង១០:០០ព្រឹក។ ករណីយឺតយ៉ាវស្ទើកស្រពន់ ពេលវេលាសវនាការជំនុំជម្រះ របស់ចៅក្រមតុលាការរាជធានី-ខេត្តនេះ បានកើតមានឡើងដដែលៗ ដូចមានបង្ហាញនៅក្នុងរបាយការណ៍ឆ្នាំ២០២៣។

| **មករា២០២២ - កក្កដា២០២៣ (១៧៥ករណី)** | | | **តុលា២០២៣ - កញ្ញា២០២៤ (៧៧ករណី)** | | |
|---|---|---|---|---|---|
| **ម៉ោងក្នុងដីកា** | **ម៉ោងជាក់ស្តែងលើស** | **ករណី** | **ម៉ោងក្នុងដីកា** | **ម៉ោងជាក់ស្តែងលើស** | **ករណី** |
| ៨:០០ព្រឹក | ១ម៉ោងកន្លះ-២ម៉ោង | ៣៨ | ៨:០០ព្រឹក | ១ម៉ោងកន្លះ-២ម៉ោង | ២៩ |
| ៨:៣០ព្រឹក | កន្លះម៉ោង-១ម៉ោង | ៨០ | ៨:៣០ព្រឹក | ២ម៉ោង-៣ម៉ោងជាង | ២៣ |
| ២:៣០រសៀល | ១ម៉ោង-ជិត២ម៉ោង | ៣៥ | ២:៣០រសៀល | ៣០នាទី-១ម៉ោង | ២៤ |

## III. សិទ្ធិក្នុងពេលជំនុំជម្រះ

**សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ**[2] យោងតាមរបាយការណ៍ ស្រាវជ្រាវបានបង្ហាញថា មាន៥៧ករណី(៧៤%)នៃ៧៧ករណី តុលាការមិនបានជូនដំណឹង អំពីសវនាការ ដោយមិនបានបិទផ្សាយនៅលើក្តារខៀនព័ត៌មានខាងក្រៅបន្ទប់សវនាការឡើយ។ លើសពីនេះទៀត ក្នុងចំណោម៧៧ករណី មានសាធារណៈជន និងអ្នកសារព័ត៌មានត្រូវបានរាំងមិនឲ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការ៖

| **ការរាំងមិនឲ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការ** | |
|---|---|
| សាធារណៈជន (១៧ករណី - ២២.១%) | អ្នកសារព័ត៌មាន (០៧ករណី - ៩.១%) |
| **មូលហេតុ៖**<br>- បន្ទប់សវនាការតូចចង្អៀត គ្មានកៅអីអង្គុយគ្រប់គ្រាន់<br>- គ្មានដីកាអញ្ជើញ ឬមិនបានចុះឈ្មោះជាមុន | |

[2] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- នគរបាលបិទទ្វាររបងមិនអនុញ្ញាតឲ្យចូល
- មិនអនុញ្ញាតឲ្យចូលដោយគ្មានហេតុផល
- តុលាការជំនុំជម្រះរឿងក្តីឯកជនដូចជាករណីរំលោភ និងករណីអនីតិជន

**សិទ្ធិដឹងពីមូលហេតុ និងបទចោទប្រឆាំងខ្លួន[3]៖** របាយការណ៍ស្រាវជ្រាវបានបង្ហាញថា មានចន្លោះពី២៣% ដល់៦២% នៃ៧៧ករណី នៅក្នុងសវនាការជំនុំជម្រះ តុលាការ(ចៅក្រម) នៅតែមិនបានអនុវត្តឲ្យបានពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ ដឹងពីមូលហេតុ កាលបរិច្ឆេទ និង ទីកន្លែងប្រព្រឹត្តបទល្មើស និងបទចោទប្រឆាំងនឹងខ្លួនឡើយ៖

| **សិទ្ធិដឹងពីមូលហេតុ និងបទចោទ (សរុប ៧៧ករណី)** | **ប្រាប់ទាំងអស់ (ករណី)** | **មិនប្រាប់ (ករណី)** | **ជាភាគរយ (%)** |
|---|---|---|---|
| ប្រាប់ពីបទចោទដែលពាក់ព័ន្ធដល់ជនជាប់ចោទគ្រប់រូប | ៣១ | ៤៦ | ៥៩.៧៤ |
| ប្រាប់ពីមាត្រាច្បាប់ពាក់ព័ន្ធ | ៥៦ | ២១ | ២៧.២៧ |
| ប្រាប់ពីកាលបរិច្ឆេទប្រព្រឹត្តបទល្មើស | ៥៧ | ២០ | ២៥.៩៧ |
| ប្រាប់ពីទីកន្លែងប្រព្រឹត្តបទល្មើស | ៥៩ | ១៨ | ២៣.៣៧ |
| ប្រាប់ពីភាគីពាក់ព័ន្ធនានាក្នុងបទល្មើស | ៥៦ | ២១ | ២៧.២៧ |
| ប្រសិនបើត្រូវការតុលាការបានផ្តល់អ្នកបកប្រែ | ២៩ | ៤៨ | ៦២.៣៤ |

**ការពន្យល់ប្រាប់ពីសិទ្ធិរបស់ជនជាប់ចោទ៖** នៅក្នុងពេលជំនុំជម្រះ ចៅក្រមហាក់បីដូចជា មិនបានពន្យល់ឲ្យបានក្បោះក្បាយ ប្រាប់អំពីសិទ្ធិជនជាប់ចោទ អំពីសិទ្ធិដែលពួកគេត្រូវទទួលបាន។ លទ្ធផលស្រាវជ្រាវបានបង្ហាញ ទិន្នន័យចន្លោះពី៣៥% និង ៦៨% នៃ៧៧ករណី ចៅក្រមខកខានមិនបានពន្យល់ប្រាប់ជនជាប់ចោទអំពីសិទ្ធិមួយចំនួនដូចជាៈ សិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួន សិទ្ធិមិនឆ្លើយ សិទ្ធិមិនបង្ខំឲ្យសារភាពកំហុស និងសិទ្ធិការសន្មត់ទុកជាមុនថាគ្មានកំហុស។ ទន្ទឹមគ្នានេះ យោងតាមទិន្នន័យបានបង្ហាញថាៈចន្លោះ ២៤% ដល់ ៥៧% នៃ៧៧ករណី ចៅក្រម គ្រាន់តែប្រាប់ត្រួសៗ អំពីសិទ្ធិដែលជនជាប់ចោទត្រូវមាន ដោយមិនពន្យល់ឲ្យបានច្បាស់លាស់ឡើយ។

| **ចៅក្រមបានប្រាប់ និងពន្យល់ជនជាប់ចោទអំពី (សរុប ៧៧ករណី)** | **ប្រាប់និងពន្យល់ (ករណី)** | **គ្រាន់តែប្រាប់ (ករណី)** | **មិនប្រាប់-មិនពន្យល់ (ករណី)** |
|---|---|---|---|
| សិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួន[4] | ០៦ | ៤៤ (៥៧%) | ២៧ (៣៥%) |
| សិទ្ធិមិនឆ្លើយ | ១០ | ៣២ (៤២%) | ៣៥ (៤៥%) |
| សិទ្ធិមិនបង្ខំឲ្យសារភាពកំហុស | ០៧ | ២៨ (៣៦%) | ៤២ (៥៥%) |
| សិទ្ធិការសន្មត់ទុកជាមុនថាគ្មានកំហុស | ០៦ | ១៩ (២៥%) | ៥២ (៦៨%) |

[3] មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[4] មាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

**សិទ្ធិហៅ និងសួរសាក្សី៖**

សាក្សីនៅក្នុងរឿងក្តី ២១ករណី (២៧%) នៃ៧៧ករណី ត្រូវបានតុលាការកោះហៅ និងស្ថិតក្នុងបន្ទប់សវនាការអំឡុងពេលសាកសួរ។ ហើយក្នុងនោះ បើតាមរបាយការណ៍បង្ហាញថា: ក្នុងសវនាការជំនុំជម្រះនៅតែឃើញមានភាពមិនប្រក្រតិបានកើតឡើងដូចជា: មាន០២ករណី (២.៣%) នៃ៧៧ករណី សាក្សីដាក់បន្ទុកត្រូវបានតុលាការយកចិត្តទុកដាក់ជាងសាក្សីដោះបន្ទុក ទន្ទឹមគ្នានោះ មាន០២ករណី (២.៣%)សាក្សីដោះបន្ទុក ដែលតុលាការយកចិត្តទុកដាក់ជាងសាក្សីដាក់បន្ទុក។

- ០៣ករណី (៣.៩%) នៃ៧៧ករណី ភាគីជនជាប់ចោទត្រូវបានហាមឃាត់ មិនឲ្យបង្ហាញភស្តុតាងជាឯកសារ រួមទាំងចម្លើយរបស់សាក្សី។
- ៤២ករណី (៥៤.៥៤%) នៃ៧៧ករណី ក្នុងសវនាការជំនុំជម្រះ តុលាការ មិនអនុញ្ញាតឲ្យភាគីជនជាប់ចោទ និងមេធាវីរបស់ជនជាប់សាកសួរសាក្សី ឬសាកសួរភាគីដើមបណ្តឹង ឬមេធាវីដើមបណ្តឹង។
- ៧៦ករណី (៩៨.៧%) នៃ៧៧ករណី ដែលភាគីជនជាប់ចោទ/មេធាវី មិនត្រូវអនុញ្ញាតឱ្យបង្ហាញភស្តុតាងជាឯកសារ រួមទាំងចម្លើយសាក្សី ទៅកាន់សាក្សីដែលបង្ហាញខ្លួនក្នុងនាមភាគីដាក់បន្ទុក ឬភាគីបណ្តឹងរដ្ឋប្បវេណី/មេធាវី។
- ០៤ករណី (៥.២%) នៃ៧៧ករណី តំណាងអយ្យការ និងភាគីជនជាប់ចោទ បានលើកឡើងពីការរារាំងការកោះហៅសាក្សី ឬការបង្ហាញភស្តុតាង។

**សិទ្ធិនៅអំឡុងពេលសួរចម្លើយនិងការហាមឃាត់ការធ្វើទារុណកម្ម[5]៖** យោងតាមរបាយការណ៍ បានបង្ហាញថា អំឡុងពេលសួរចម្លើយ នៅតំណាក់កាលនគរបាលយុត្តិធម៌ ០៧ នៃ៧៧ករណី មានការគំរាមកំហែងឲ្យ សារភាព និងផ្តិតមេដៃលើរបាយការណ៍ នៅតំណាក់កាលនគរបាលយុត្តិធម៌ (តែចុងចោទបានធ្វើការបដិសេធចម្លើយរបស់ខ្លួននៅតំណាក់កាលចៅក្រមស៊ើបសួរ)។

| **ជនជាប់ចោទត្រូវបាន (សរុប៧៧ករណី)** | **មិនមាន** | **មាន** | **បញ្ជាក់មូលហេតុ (មាន)** |
|---|---|---|---|
| សួរចម្លើយដោយគ្មានវត្តមានមេធាវី | ៧០ | ០៧ | ជនជាប់ចោទទើបស្នើសុំមេធាវីនៅដំណាក់កាលចៅក្រមស៊ើបសួរ |
| គំរាមកំហែងឲ្យសារភាព | ៧០ | ០៧ | ជនជាប់ចោទបានប្រាប់ថា: នគរបាលបង្ខំឲ្យសារភាព និងផ្តិតមេដៃលើរបាយការណ៍ |
| ទទួលរងអំពើហឹង្សា ឬទារុណកម្មបង្ខំឲ្យសារភាព | ៧៦ | ០១ | ជនជាប់ចោទបានប្រាប់ថា: នគរបាលស្រុកដាក់ខ្នោះដៃ បង្ខំឲ្យសារភាព |

**ការសន្និតទុកជាមុនថាគ្មានទោស [6] ៖** យោងតាមរបាយការណ៍ បានបង្ហាញថាមាន ០៦ករណី នៃ៧៧ករណី ចៅក្រមជំនុំជម្រះ និយាយពីភាពមានពិរុទ្ធរបស់ជនជាប់ចោទមុនពេលចេញសាលក្រម ដោយចៅក្រមជំនុំជម្រះ "បានប្រាប់ឲ្យជនជាប់ចោទទទួលកំហុស...ចៅក្រមព្រមទាំងនិយាយអំពីទោសត្រូវជាប់ព័ន្ធនាគារអាច

[5] មាត្រា១ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងមាត្រា៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ និងមាត្រា៣៨ នៃរដ្ឋធម្មញ្ញព្រះរាជាណាចក្រកម្ពុជា

[6] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា១១ នៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស

ពី៧ឆ្នាំ ទៅ១៥ឆ្នាំ...ហើយស្នើឲ្យដើមចោទដកពាក្យបណ្តឹង"។ ទន្ទឹមនោះ មាន២៣ នៃ ៧៧ករណី ជនជាប់ចោទ បង្ហាញខ្លួននៅអំឡុងពេលសវនាការក្នុងឯសណ្ឋានពន្ធនាគារ (មានឯសណ្ឋានពណ៌ខៀវ និងពណ៌ទឹកក្រូច) និង ០២ នៃ៧៧ករណី ជនជាប់ចោទត្រូវបានពាក់ខ្នោះដៃក្នុងអំឡុងពេលសវនាការ (ដោយមូលហេតុនគរបាលភ្លេចដោះខ្នោះដៃចេញពេលចូលសវនាការ)។

| ជនជាប់ចោទបង្ហាញខ្លួន (សរុប៧៧ករណី) | មិនមាន | មាន | បញ្ជាក់មូលហេតុ (មាន) |
|---|---|---|---|
| អំឡុងពេលសវនាការក្នុងឯកសណ្ឋានពន្ធនាគារ | ៥៤ | ២៣ | - ឯកសណ្ឋានពណ៌ខៀវ<br>- ឯកសណ្ឋានពណ៌ទឹកក្រូច |
| ជាប់ខ្នោះក្នុងអំឡុងពេលសវនាការ | ៧៥ | ០២ | - នគរបាលភ្លេចដោះខ្នោះដៃចេញ ពេលជនជាប់ចោទឡើងទៅរង្វង់ក្រចកសេះ បន្ទាប់ពីពាក់នៅពេលរងចាំសវនាការ |
| ចៅក្រមបាននិយាយពីភាពមានឬគ្មានទោសជនជាប់ចោទមុនពេលចេញសាលក្រម | ៧១ | ០៦ | - ចៅក្រមជំនុំជម្រះបានប្រាប់ឲ្យជនជាប់ចោទទទួលកំហុស<br>- ចៅក្រមនិយាយពីទោសពន្ធនាគារ អាចពី៧ឆ្នាំ ទៅ ១៥ឆ្នាំ ហើយស្នើឲ្យដើមចោទដកពាក្យបណ្តឹង |
| ចៅក្រមទាញពិរុទ្ធភាពពីការនៅស្ងៀមរបស់ជនជាប់ចោទ | ៧៧ | ០០ | |

## IV ការប្រតិបត្តិរបស់មេធាវី

- ៥៣ នៃ៧៧ករណី មេធាវីតំណាងដោយអាណិត្ត មានវត្តមាន អំឡុងពេលសវនាការលើកលែងតែ ២៤ករណី ប៉ុណ្ណោះដែលសវនាការប្រព្រឹត្តដោយគ្មានមេធាវី ដោយសារជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានស្នើសុំមេធាវី មេធាវីអវត្តមាន និងមេធាវីមិនបានទទួលលិខិតអញ្ជើញ។ ហើយនៅក្នុងនោះមាន១៦ករណី ដែលមេធាវីតំណាងឲ្យជនជាប់ចោទលើសពីម្នាក់ "មេធាវីម្នាក់ការពារឲ្យជនជាប់ចោទមួយក្រុមដែលភាគច្រើន គឺជាតំណាងសហគមន៍វិវាទដីធ្លី ធនធានធម្មជាតិ និងសេរីភាពមូលដ្ឋាន"។
- ៤២ករណី មេធាវី បានព្យាយាមតវ៉ាដើម្បីឲ្យកូនក្តីខ្លួន មានឱកាសការពារខ្លួនដោយខ្លួនឯង ទន្ទឹមនោះក៏មាន ៣៥ករណី ដែលមេធាវីមិនសូវយកចិត្តទុកដាក់ក្នុងការតវ៉ាដើម្បីឲ្យកូនក្តីខ្លួន មានឱកាសការពារខ្លួនដោយខ្លួនឯងដែរ។
- ២១ករណី មេធាវីបានលើកឡើងអំពីសិទ្ធិទទួលបាន ការជំនុំជម្រះដោយយុត្តិធម៌របស់កូនក្តីរបស់ខ្លួន ដូចជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិដឹងពីបទចោទនិងសិទ្ធិមានវត្តមានពេលសវនាការ។

- ៣៧ករណី មេធាវី បាននិយាយយោងច្បាប់អន្តរជាតិក្នុងពេលសវនាការ ដូចជាសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ ជាដើម។
- ៣៥ករណី មេធាវី បានលើកឡើងអំពីភាពមិនពេញលេញ និងមិនស៊ីសង្វាក់នៃភស្តុតាង។
- ០២ករណី មេធាវី បានប្រើទូរស័ព្ទដៃនៅក្នុងពេលសវនាការ ហើយ០១ករណីមេធាវីបានដើរដើរចាកចេញពីបន្ទប់សវនាការទៅនិយាយទូរស័ព្ទនៅខាងក្រៅ។

**ឯករាជ្យភាព ភាពមិនលំអៀង និងការប្រព្រឹត្តរបស់ចៅក្រមលើភាគីពាក់ព័ន្ធ ៖** យោងតាមរបាយការណ៍ បានបង្ហាញថា មាន៣១.១៦% (២៤ នៃ៧៧ករណី) ចៅក្រម និង តំណាងអយ្យការ បានប្រើប្រាស់ទូរស័ព្ទដៃអំឡុងពេលសវនាការ។ មាន ១៩.៤៨% (១៥ នៃ៧៧ករណី) ចៅក្រម និងតំណាងអយ្យការ បានដើរចាកចេញពីបន្ទប់សវនាការ ដោយមូលហេតុ ទៅបន្ទប់ទឹក និងចេញទៅខាងក្រៅជាដើម។ ១១.៧% (០៩ នៃ៧៧ករណី) ចៅក្រម និងតំណាងអយ្យការ នៅតែសម្តែងអាកប្បកិរិយាសម្លុតគំរាមដល់ជនជាប់ចោទអំឡុងពេលសវនាការដូចជា ឲ្យជនជាប់ចោទទទួលកំហុស និងថា: *សំនួរនុះមិនសួរទេ កុំឆ្លើយ ត្រូវឆ្លើយសំនួរណាដែលសួរបានហើយ...និងប្រើសម្តីខ្លាំងៗថា: ដឹងថាខ្លួនមានកំហុសទេ!*។ ៤%(០៣ នៃ៧៧ករណី)ចៅក្រម និងតំណាងអយ្យការ បានប្រើពាក្យពេជន៍បែបរើសអើងទៅកាន់ជនជាប់ចោទជាជាតិពន្ធុ និងស្តីបន្ទោសលើភេទជាដើម ។

| ចៅក្រម/តំណាងអយ្យការបាន (សរុប៧៧ករណី) | មិនមាន | មាន | បញ្ជាក់មូលហេតុ (មាន) |
|---|---|---|---|
| សម្តែងអាកប្បកិរិយា សម្លុតគំរាមដល់ភាគីជនជាប់ចោទ | ៦៨ | ០៩ | - ប្រើពាក្យសម្តីខ្លាំងៗ(សម្លុត)ដាក់ចុងចម្លើយ "*សំនួរនុះមិនសួរទេ កុំឆ្លើយ ត្រូវឆ្លើយសំនួរណាដែលសួរបានហើយ*"<br>- ប្រើសម្តីខ្លាំងៗ: ដឹងថាខ្លួនមានកំហុសទេ! |
| ប្រើពាក្យពេជន៍បែបរើសអើងទៅកាន់ភាគីជនជាប់ចោទ | ៧៤ | ០៣ | - ស្តីបន្ទោសលើភេទចុងចម្លើយ<br>- ទៅលើជនជាប់ចោទជាតិពន្ធុ |
| ចាកចេញពីបន្ទប់អំឡុងពេលសវនាការ | ៦២ | ១៥ | - ចៅក្រម ១០ករណី<br>- តំណាងអយ្យការ ០៥ករណី<br>- មូលហេតុ: ទៅបន្ទប់ទឹក និងទៅខាងក្រៅ |
| ប្រើទូរស័ព្ទអំឡុងពេលសវនាការ | ៥៣ | ២៤ | - តំណាងអយ្យការ ១២ករណី និងចៅក្រម ១២ករណី<br>- ១៥ករណី គ្រាន់តែឆ្លើយតបទូរស័ព្ទខ្លីហើយដាក់ចុះវិញ និងសន្ទនាយូរ១ករណី<br>- មានសម្លេងរោទ៍០៤ និងញ័រ២០ករណី |

**ការពិភាក្សាសម្រេចរបស់តុលាការ៖** មាន៦.៥% (០៥ នៃ៧៧ករណី) ចៅក្រមបានធ្វើការពិភាក្សាសម្រេចអំឡុងពេលការពិភាក្សាសម្រេចរបស់ចៅក្រម។ ២៦% (២០ នៃ៧៧ករណី) ត្រូវបានតុលាការលើកពេលប្រកាសសាលក្រម ហើយក្នុងនោះមាន០២ករណី ដែលតុលាការលើកពេលប្រកាសសាលក្រម ដោយមិនបានបញ្ជាក់អំពីកាលបរិច្ឆេទច្បាស់លាស់។

**សាលក្រម៖** យោងតាមរបាយការណ៍បានបង្ហាញថា មាន១.៣% (០១ នៃ៧៧ករណី) ចៅក្រមបានបន្ថែមបទល្មើសថ្មីនៅពេលប្រកាសសាលក្រម និង ២.៦% (០២ នៃ៧៧ករណី) ចៅក្រមបានផ្លាស់ប្តូរបទចោទលើជនជាប់ចោទនៅពេលប្រកាសសាលក្រម។

| ចៅក្រមបាន (សរុប៧៧ករណី) | មិនមាន | មាន | ភាគរយ: (មាន) |
|---|---|---|---|
| យោងមាត្រាច្បាប់ដែលជនជាប់ចោទត្រូវបានកាត់ទោស | ៤៧ | ៣០ | ៣៩% |
| បង្ហាញភស្តុតាងដែលនាំឲ្យមានការសម្រេចផ្តន្ទាទោស | ៥៩ | ១៨ | ២៣.៣៧% |
| ផ្លាស់ប្តូរបទចោទលើជនជាប់ចោទនៅពេលប្រកាសសាលក្រម | ៧៥ | ០២ | ២.៦% |
| បន្ថែមបទល្មើសថ្មីនៅពេលប្រកាសសាលក្រម | ៧៦ | ០១ | ១.៣% |

| **របាយការណ៍មេធាវីតំណាងសមាគមអាដហុក** | |
|---|---|
| ១ | **<u>កត្តាប៉ះពាល់ធ្ងន់ធ្ងរដល់ការស្វែងរកយុត្តិធម៌៖</u>** ជនសង្ស័យឬជនត្រូវចោទប្រើមធ្យោបាយដាក់ពាក្យពន្យាពេលចូលឆ្លើយបំភ្លឺ និង/ឬសវនាការ ដោយពួកគាត់គ្មានពេលគ្រប់គ្រាន់ស្វែងរកមេធាវីការពារក្ដីដោយមិនយកកម្រៃ ទន្ទឹមនោះ មេធាវីគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាសំណុំរឿងត្រៀមខ្លួនការពារក្ដី:<br>- ៨៥% នៅដំណាក់កាលចៅក្រមស៊ើបសួរ ចៅក្រមកោះហៅតែកូនក្ដីដោយមិនចេញលិខិតអញ្ជើញមេធាវីតំណាងចូលរួម។<br>- ៧០% ចៅក្រមស៊ើបសួរ និង/ឬ ចៅក្រមជំនុំជម្រះ មានការយឺតយ៉ាវក្នុងការកោះហៅ[7] កូនក្ដី និងចេញលិខិតអញ្ជើញមេធាវីឲ្យចូលអមកូនក្ដី និងចូលរួមសវនាការ។<br>- ៧០% នគបាលប៉ុស្ដិ៍រដ្ឋបាល យឺតយ៉ាវក្នុងការប្រគល់ដីកាកោះរបស់តុលាការឲ្យកូនក្ដីត្រឹមតែមួយថ្ងៃមុនថ្ងៃសវនាការ ឬថ្ងៃចូលខ្លួនទៅបំភ្លឺ។<br>- ចៅក្រមលើកពេលសវនាការជំនុំជម្រះ មិនបានផ្ដល់ដំណឹងជាមុនដល់មេធាវី និងកូនក្ដី។ |
| ២ | **<u>ឧបសគ្គមេធាវីក្នុងការសិក្សាសំណុំរឿង៖</u>** ៨៥% ករណីសិទ្ធិមនុស្ស និងករណីដីធ្លីធំៗដែលមានការពាក់ព័ន្ធបញ្ហានយោបាយ មិនអនុញ្ញាតឲ្យមេធាវីថតចម្លងសំណុំរឿងពេញលេញ ក្រោមមូលហេតុ: ចៅក្រមឬព្រះរាជអាជ្ញា មិនទាន់បានពិនិត្យ ឬមិនទាន់បានចុះហត្ថលេខា ឬជារឿងសម្ងាត់ ឬត្រូវសុំការអនុញ្ញាតពីថ្នាក់លើជាមុនសិន( សួរមេ )។ |
| ៣ | **<u>ការខកខានមិនបានជូនដំណឹងរបស់តុលាកា</u>** [8] **៖** ជាង៩០% តុលាការ(មន្ត្រីតុលាការ តំណាងអយ្យការ ចៅក្រមស៊ើបសួរ) មិនជូនដំណឹងមេធាវី អំពីដីកាសម្រេចដូចជា: ដីកាតម្កល់រឿងមិនចាត់ការ ដីកាដំណោះស្រាយបិទការស៊ើបសួរ ដីការសម្រេចឃុំខ្លួន ដីកាដាក់ឲ្យកូនក្ដីស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដីកាសន្និដ្ឋានស្ថាពរ ដីកាដំណោះស្រាយ។ |
| ៤ | **<u>កត្តាប៉ះពាល់ប្រយោជន៍កូនក្ដីក្នុងការស្វែងរកយុត្តិធម</u>[9]៖** ការមិនអនុញ្ញាតឲ្យសាក្សីដោះបន្ទុកចូលធ្វើសក្ខីកម្មបញ្ជាក់ ចៅក្រមជំនុំជម្រះ មិនអនុញ្ញាតឲ្យ-មិនកោះហៅ សាក្សីដោះបន្ទុក ដែលមេធាវីបានដាក់ស្នើតាំងពីតំណាក់កាលស៊ើបសួរ និងតំណាក់កាលជំនុំជម្រះ។ កាលបើតុលាការ ប្រើតែកំណត់ហេតុ របស់មន្ត្រីនគរបាលយុត្តិធម៌តែម្ខាង នោះអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ។ |

[7] យោង មាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះរឿងក្ដីព្រហ្មទណ្ឌ បើសំណុំរឿងស្ថិតក្នុងដៃព្រះរាជអាជ្ញា និងចៅក្រមជំនុំជម្រះ និង មាត្រា ២៣៦, ២៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌបើស្ថិតក្នុងដៃចៅក្រមស៊ើបសួរ។

[8] យោងមាត្រា ២៣៦ និងមាត្រា២៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[9] យោងមាត្រា ១១០ និង ១១៨ និងមាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## V. អនុសាសន៍

1. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការ ទាំងឡាយណា ដែលផ្ទុយនឹងគោលបំណង មាត្រា២០៨ និងមាត្រា២០៩ នៃនីក្រមតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងអំពីថេរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន ។ បើយោងរបាយការណ៍បានបង្ហាញថា នៅតែមានការឃុំខ្លួនបណ្តោះអាសន្នមានថិរវេលាលើសពី៦ខែ រហូតដល់ជាង១៨ខែ មានចំនួន៤២ករណី(៥៤.៥៤%) ក្នុងចំណោម៧៧ករណី បើធៀបរបាយការណ៍ចុងឆ្នាំ២០២៣ កើន៨.៨៣% (៨០ករណី នៃករណីសរុប១៧៥)។
2. ក្រសួងយុត្តិធម៌ពិនិត្យ និងដាក់ពិន័យរដ្ឋបាលធ្ងន់ធ្ងរចំពោះចៅក្រម និងតំណាងអយ្យការទាំងឡាយណាដែលមានការយឺតយ៉ាវចំពោះពេលវេលាបំពេញភារកិច្ចការងារ បើកសវនាការជំនុំជម្រះ ។ យោងតាមរបាយការណ៍បានបង្ហាញថា តុលាការ(ចៅក្រម) នៅតែបន្តភាពយឺតយ៉ាវ ក្នុងការចាប់ផ្តើមសវនាការជាក់ស្តែង ខុសពីម៉ោងដែលបានកំណត់នៅក្នុងដីកា ចាប់ពី មួយម៉ោងកន្លះ រហូតដល់ជាងបីម៉ោង។
3. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការទាំងឡាយណា ដែលមានការយឺតយ៉ាវក្នុងការចេញលិខិតអញ្ជើញមេធាវី និងភាគីចូលរួមក្នុងសវនាការជំនុំជម្រះ។
4. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការទាំងឡាយណាដែលខកខាន មិនបានអញ្ជើញមេធាវីចូលរួមអមកូនក្តី ដើម្បីស្តាប់ចម្លើយកូនក្តីនៅតំណាក់កាលព្រះអាជ្ញា។
5. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះការអនុវត្តន៍របស់ចៅក្រម និងតំណាងអយ្យការ ទាំងឡាយណាដែលខកខានមិនបានជូនដំណឹងអំពីដីកាសម្រេច ដូចជាដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ។
6. ចៅក្រម-តំណាងអយ្យការ ពិចារណាក្នុងការប្រើពាក្យ ឬនិយាយពីភាពមានឬគ្មានទោសដល់ជនជាប់ចោទ មុនពេលចេញសាលក្រម ជាពិសេសដូចជា ប្រាប់ឲ្យជនជាប់ចោទទទួលកំហុស និងប្រាប់ឲ្យដើមបណ្តឹងដកពាក្យបណ្តឹង។
7. ចៅក្រមពិនិត្យ-ពិចារណា អំពីសិទ្ធិរបស់ជនជាប់ចោទដូចជា ជនជាប់ចោទមានពាក់ឯកសណ្ឋានពន្ធនាគារ និងដៃជាប់ខ្នោះ ក្នុងអំឡុងពេលសវនាការជំនុំជម្រះ។
8. ចៅក្រមពន្យល់ប្រាប់ជនជាប់ចោទ-ជនរងគ្រោះ ឲ្យបានច្បាស់លាស់ អំពីសិទ្ធិដែលត្រូវទទួលបានដូចជា សិទ្ធិមានមេធាវី សិទ្ធិមិនឆ្លើយ សិទ្ធិមិនបង្ខំឲ្យសារភាពកំហុស និងសិទ្ធិសន្មត់ទុកជាមុនថា គ្មានកំហុស សិទ្ធិដឹងពីបទចោទ សិទ្ធិដឹងការបរិច្ឆេទ-ទីកន្លែងប្រព្រឹត្តបទល្មើសជាដើម។
9. ក្រសួងយុត្តិធម៌ ពិនិត្យដាក់វិធានការណ៍ច្បាស់លាស់ ចំពោះគ្រប់សាលាដំបូង ក្នុងការបើកចំហរដល់សាធារណៈជន និងអ្នកសាពត៌មានបានចូលស្តាប់សវនាការសាធារណៈ ដោយគ្មានការហាមឃាត់ និងបណ្តេញចេញ។

# TRIAL OBSERVATION



Capital-Provincial Courts of First Instance (October 1, 2023 – September 30, 2024)

**Phnom Penh, January 15, 2024**

Address: # 3, Street 158, Oknha Treng Kong, Sangkat Boeung Reang, Khan Daun Penh, Phnom Penh.
Phone: (+ 855-23) 218 553/210 518/990 544
P.O Box: 1024 - P.O Box 20 at CCC
Email: info@adhoccambodia.org
Website: www.adhoccambodia.org
Facebook: www.facebook.com/adhoccam
Twitter: www.twitter.com/adhoccam

# TABLE OF CONTENTS


**I. Introduction** ........ 15

**II. General information and parties involved in the case** ........ 15

**III. Rights during trial** ........ 17

**IV. Lawyer execution** ........ 19

**V. Recommendations** ........ 22

## I. Introduction

**About ADHOC:** Cambodian Human Rights and Development Association (ADHOC) is an independent, neutral, non-profit, and non-partisan non-governmental organization. ADHOC is the first human rights organization established in Cambodia on December 10, 1991, and officially recognized by King Norodom Sihanouk on March 10, 1992, and registered with the Ministry of Interior on March 28, 2000, under Prakas No. 278.

ADHOC operates nationwide, with its headquarters in Phnom Penh and branches in 21 target provinces: 1. Prey Veng, 2. Kampong Cham, 3. Kratie, 4. Stung Treng, 5. Ratanakiri, 6. Mondulkiri, 7. Kampot, 8. Koh Kong, 9. Preah Sihanouk, 10. Kampong Thom, 11. Kampong Chhnang, 12. Battambang, 13. Banteay Meanchey, 14. Udor Meanchey, 15. Siem Reap, 16. Preah Vihear, 17. Kampong Speu, 18. Pursat, 19. Pailin, 20. Svay Rieng, and 21. Tbaung Khmum.

ADHOC works to promote respect for, protection of, and adherence to fundamental human rights, fundamental freedoms, and democracy in Cambodia. This is achieved by providing citizens with knowledge and understanding of human rights, the law, democracy, and methods to protect their rights and freedoms; observing and intervening in cases of human rights abuses; offering free counseling and legal services. The main purpose of ADHOC is to empower victims of abuse to seek justice independently, strengthen the capacity of citizens to demand their rights, and encourage public participation in advocating for, promoting, and peacefully improving laws, institutions, and law enforcement.

**Method:** The 'Trial Observation' report was compiled using information gathered from the Trial Observation Reports of ADHOC officers, facilitators, and offices in provinces and the capital, covering nationwide activities, who were present at the trials in person. All cases in which ADHOC workers participated in the trials in person fell within the association's mandate. These cases involved legal services (lawyers) provided by ADHOC for mandated legal representation and defense, at the request of the victims. A 19-question trial observation form was developed to document events during the trial observation. These documented reports were submitted to the Phnom Penh headquarters. The data were then entered into the Statistical Package for the Social Sciences (SPSS) for analysis and report compilation.

**Purpose:** The "Trial Observation" report is designed to contribute to the promotion of the right to justice in a transparent manner and to ensure the absence of four types of partiality. Specifically, it aims to provide findings related to the judicial performance of judges, prosecutors, and lawyers, with the goal of improving the judicial system in Cambodia.

## II. General information and parties involved in the case

**The "Trial Observation"** Report covers only the scope within the Trial Chamber of the Capital-Provincial Courts of First Instance, "Provincial-Capital Courts", where trial observations were conducted from October 2023 to September 2024.

During the reporting period, ADHOC workers observed 77 trial cases across 17 Capital-Provincial Courts, in which lawyers representing ADHOC acted as attorneys-in-fact for victims. These courts included those in Phnom Penh, Banteay Meanchey, Mondulkiri, Prey Veng, Pursat, Ratanakiri, Siem Reap, Sihanoukville, Stung Treng, Battambang, Udor Meanchey, Tbaung Khmum, Kampong Cham, Kampong Chhnang, Kampong Speu, Kandal, and Koh Kong provinces.

ADHOC observed trials and provided defense lawyers for the 77 cases. These include **29 (38%) cases related to general human rights violations, 16 (21%) cases of land rights violations, and 32 (41%) cases concerning violations of the rights of women and children**. Among these, 50 cases involved the intimidation of political activists, which constitutes the majority, along with cases of intimidation of human rights activists, land grabbing by powerful individuals, and illegal arrests.

Of the 77 cases in which ADHOC observed trials and provided legal counsel, 40 were criminal cases and 37 were misdemeanors (none involving minor offenses). The total number of defendants/victims was 328 (78 women, 14 children, with 63 absent during the hearing), and there were 106 plaintiffs/victims (42 women, 7 children, with 11 absent during the hearing).

**Adjournment of Hearing:** Of the 77 cases, 38 were trialed by a single judge and 39 by counseling judges. Thirteen cases (17%) were adjourned due to reasons such as the illness or scheduling conflicts of the counseling judges, the absence of witnesses, the failure of the accused to provide answers during the phase of the investigating judge, or the court's request for additional evidence

**Provisional detention for 6 months[10]:** Of the 77 cases, 42 involved accused individuals who were provisionally detained. According to the report, by the date of the hearing, provisional detention had still exceeded the period allowed by law in 42 cases (54.6%) among 77 cases at the Capital-Provincial Courts. This is compared to the report at the end of 2023, which showed provisional detention exceeding the legal limit in 80 cases (45.71%) out of 175 cases, **<u>indicating an increase of 8.89% from the previous year</u>**:

| **January 2022 - July 2023 (175 cases)** | | **October 2023 - September 2024 (77 cases)** | |
|---|---|---|---|
| Number of months of overdue detention | Cases (80) | Number of months of overdue detention | Case (42) |
| Between more than 6 months - 9 months | 34 | Between more than 6 months - 9 months | 22 |
| Between more than 10 months - 12 months | 12 | Between more than 10 months - 12 months | 03 |
| Between more than 18 months - 23 months | 02 | Over 18 months | 02 |
| More than 24 months | 32 | Between more than 3 months - 6 months | 15 |

**The difference between the time specified in the court order and the actual time the trial is opened:** According to the report, the Capital-Provincial courts, particularly the trial judges, **still** delayed the actual trials beyond the time specified in the summons/order. Delays ranged from half an hour to two hours. For example, if the summons/order stipulated that the trial should begin at 8:00 a.m. as a mandatory time, the actual start time might be as late as 9:30 or even 10:00 a.m. Cases of excessive delays in the trial times by the Capital-Provincial courts have occurred repeatedly, as shown in the 2023 report.

[10] Article 208, Article 209, Article 249, Article 283 and Article 305 of the 2007 Criminal Procedure Code and Article 14 of the International Covenant on Civil and Political Rights

| January 2022 - July 2023 (175 cases) | | | October 2023 - September 2024 (77 cases) | | |
|---|---|---|---|---|---|
| **Time in the court order** | **Actual time of delay** | **Case** | **Time in the court order** | **Actual time of delay** | **Case** |
| 8:00 a.m | 1 hour and a half - 2 hours | 38 | 8:00 a.m | 1 hour and a half - 2 hours | 29 |
| 8:30 a.m | Half an hour - 1 hour | 80 | 8:30 a.m | 2 hours - 3 hours more | 23 |
| 2:30 p.m | 1 hour - almost 2 hours | 35 | 2:30 p.m | 30 minutes - 1 hour | 24 |

## III. Rights during trial

**The right to a public trial**[11]: According to the investigation report, in 57 (74%) of the 77 cases, the court did not notify the hearing by posting it on the information board outside the courtroom. Additionally, in some of the 77 cases, the public and journalists were either barred from entering or evicted from the courtroom:

| Barred entry or eviction from the courtroom | |
|---|---|
| The Public (17 cases - 22.1%) | Journalists (07 cases - 9.1%) |
| **Reasons:**<br>- The courtroom was narrow or lacked sufficient seats.<br>- There was no invitation or pre-registration.<br>- The police closed the gates to prevent entry.<br>- Entry was not allowed without explanation.<br>- The court was hearing private cases, such as rape and juvenile cases. | |

**The rights to be informed of the nature and cause of the charge(s)**[12]**:** The investigation report shows that between 23% and 62% of the 77 cases in court (judge) trial still do not fully uphold the rights of the accused to be informed of the cause, date, place of the offense, and the charges against them:

| The right to be informed of the nature and cause of the charge(s) (77 cases in total) | All informed (Case) | Not informed (Case) | Percentage (%) |
|---|---|---|---|
| Inform all the accused of the related charges | 31 | 46 | 59.74 |
| Informed of the related articles of law | 56 | 21 | 27.27 |
| Informed of the date on which the offense was committed | 57 | 20 | 25.97 |
| Informed of the place where the offense was committed | 59 | 18 | 23.37 |
| Informed of the parties involved in the offense | 56 | 21 | 27.27 |
| If needed, the court provided an interpreter | 29 | 48 | 62.34 |

**Explanation of the rights of the accused:** During the trial, the judges did not appear to explain in detail the rights of the accused that could be received. Investigation results show that in 35% to 68% of the 77 cases reviewed, judges failed to inform the accused of some fundamental rights. These include the right to legal representation, the right to self-defense, the right to remain silent, the right not to be coerced into admitting guilt, and the right to the presumption of innocence. Additionally, data indicate that in 24% to 57% of the

[11] Article 316 of the 2007 Criminal Procedure Code

[12] Article 325 of the Criminal Procedure Code 2007

77 cases, judges provided only a brief explanation of the rights of the accused, without offering clear and thorough guidance.

| The judge informed the accused and explained (77 cases in total) | Informed and explained (Case) | Only informed (Case) | Failed to inform and explain (case) |
|---|---|---|---|
| The right to legal representation or the right to self-defense[13] | 06 | 44 (57%) | 27 (35%) |
| The right to remain silent | 10 | 32 (42%) | 35 (45%) |
| The right not to be coerced into admitting guilt | 07 | 28 (36%) | 42 (55%) |
| The right to the presumption of innocence | 06 | 19 (25%) | 52 (68%) |

**The right to call and question witnesses:**

In 21 cases (27%) out of the 77 cases, witnesses were summoned by the court and were present in the courtroom during questioning. The report highlights the following irregularities: In 2 cases (2.3%) of the 77, the court gave more attention to incriminating witnesses than to exculpatory witnesses. Similarly, in another 2 cases (2.3%), the court gave more attention to exculpatory witnesses than to incriminating witnesses.

- In 3 cases (3.4%) out of the 77 cases, the accused were barred from presenting documentary evidence, including witness testimony.
- In 42 cases (54.54%) out of the 77 trial cases, the accused and their lawyers were not allowed to cross-examine witnesses or the plaintiffs and their lawyers.
- In 76 cases (98.7%) out of the 77, the defendants and their lawyers were not allowed to present documentary evidence, including witness testimony, from witnesses appearing on behalf of the parties or civil parties and their lawyers.
- In 4 cases (5.2%) out of the 77 cases, both the prosecution representatives and the accused indicated that the summoning of witnesses or presentation of evidence was prevented.

**Rights during the questioning and ban on torture[14]** According to the report, during questioning at the Judicial Police stage, in 7 out of 77 cases, there were threats to obtain confessions and thumbprints on reports (however, the accused denied these statements during the Investigating judge stage).

| The accused were (77 cases in total) | No | Yes | Specify the reason (yes) |
|---|---|---|---|
| Questioned in the absence of legal representation | 70 | 07 | The accused only requested legal representation at the investigating judge stage |
| Coerced into confessing | 70 | 07 | The accused stated that the police coerced them into confessing and providing thumbprints on reports |
| Coerced into making a confession through the use of violence or torture | 76 | 01 | The accused stated that the district police handcuffed him and coerced him into confessing |

[13] Article 301 of the Criminal Procedure Code 2007

[14] Article 1 of the Convention against Torture and Article 5 of the Universal Declaration of Human Rights, and Article 14 of the International Covenant on Civil and Political Rights and Article 38 of the Constitution of the Kingdom of Cambodia

**Presumption of innocence[15]:** According to the report, in 6 out of 77 cases, the trial judge spoke about the guilt of the accused before issuing the verdict. The judge reportedly told the accused to "accept their guilt …, spoke about the potential sentence of imprisonment ranging from 7 to 15 years …, and asked the plaintiff to withdraw the complaint. Meanwhile, in 23 out of 77 cases, the accused appeared during the hearings in prison uniforms (blue and orange). In 2 out of 77 cases, the accused were handcuffed during the hearings (due to the police forgetting to remove the handcuffs before entering the hearing room).

| **The accused appeared (77 cases in total)** | **No** | **Yes** | **Specify the reason (yes)** |
|---|---|---|---|
| During the hearing in prison uniforms | 54 | 23 | - Blue uniform<br>- Orange uniform |
| Handcuffed during the hearing | 75 | 02 | - The police forgot to remove the handcuffs when the accused went to the dock after being handcuffed while waiting for the trial |
| The judge commented on the guilt or innocence of the accused before issuing the verdict | 71 | 06 | - The trial judge told the accused to accept their guilt<br>- The judge commented on the potential sentence of imprisonment, ranging from 7 to 15 years, and asked the plaintiff to withdraw their complaint |
| The judge inferred the guilt of the accused from their silence | 77 | 00 | |

## IV. Lawyer execution

- In 53 of the 77 cases, the lawyer was present during the hearing, except for 24 cases where the hearing was conducted without a lawyer for the reason that the victim or Civil Party did not request a lawyer, the lawyer was absent, or the lawyer did not receive an invitation. In 16 cases, a single lawyer represented more than one accused individual. In these cases, the lawyer defended a group of accused individuals, most of whom were from communities involved in disputes related to land, natural resources, and fundamental freedoms.
- In 42 cases, lawyers attempted to protest in order to give their clients a chance to defend themselves, while in 35 cases, lawyers failed to give much attention to enabling their clients to have the opportunity to defend themselves.
- In 21 cases, the lawyer commented on their client's right to a fair trial, including the right to be informed of the charges and the right to be present at the hearing.
- In 37 cases, lawyers referred to international law during the trial, including the Universal Declaration of Human Rights and the International Covenant on Civil and Political Rights.
- In 35 cases, the lawyer cited the incompleteness and inconsistency of the evidence."
- In two cases, the lawyer used a cell phone during the hearing, and in one case, the lawyer got up and left the courtroom to speak on the phone outside.

[15] Article 38 of the Constitution of the Kingdom of Cambodia and Article 14 of the International Covenant on Civil and Political Rights and Article 11 of the Declaration of Human Rights

**Independence, Impartiality, and Conduct of Judges Regarding Related Parties:** According to the report, 31.16% (24 out of 77 cases) of judges and prosecutors used mobile phones during the trial. In 19.48% (15 out of 77 cases), judges and prosecutors walked out of the courtroom for reasons such as going to the bathroom or stepping outside. In 11.7% (9 out of 77 cases), judges and prosecutors exhibited intimidating behavior towards the accused during the trial, such as pressuring the accused to admit guilt and instructing them, "*That question was not asked, so do not answer, only answer the questions that are asked," and using strong language, such as, "Do you know that you are guilty?"*. In 4% (3 out of 77 cases), judges and prosecutors used discriminatory language against the accused, who were ethnic minorities, or blamed them for their gender.

| Judges / Prosecutors (77 cases in total) | Yes | No | Specify the reason (yes) |
|---|---|---|---|
| Exhibited intimidating behavior towards the accused | 68 | 09 | - Used strong language (intimidation) against the defendant "*That question was not asked, so do not answer, only answer the questions that are asked"*<br>- Used strong language: Do you know that you are guilty! |
| Used discriminatory language against the accused | 74 | 03 | - Blamed the defendant for their gender<br>- Against the accused, who were ethnic minorities |
| Left the room during the hearing | 62 | 15 | - Judges in 10 cases<br>- Representative of the Prosecution in 5 cases<br>- Reason: Going to bathroom or stepping outside |
| Used a cell phone during the hearing | 53 | 24 | - Prosecutors in 12 cases and judges in 12 cases<br>- Just briefly answered the phone and then hanged up in 15 cases and 1 long conversation in 20 cases<br>- Ringtones in 4 cases and vibrations in 20 cases |

**Court discussion & decision:** In 6.5% (5 out of 77 cases), judges discussed and made decisions during their deliberations. In 26% (20 out of 77 cases), the court adjourned proceedings for the issuance of verdicts, with 2 of these cases being adjourned without a specific date provided.

**Verdict:** According to the report, in 1.3% (1 out of 77 cases), judges added new offenses when pronouncing the verdict. In 2.6% (2 out of 77 cases), judges changed the charges against the accused when issuing the verdict.

| The judge (Total 77 cases) | Yes | No | Period (Available) |
|---|---|---|---|
| Referred to the articles of law on which the convictions of the accused were based | 47 | 30 | 39% |
| Presented evidence that supported the decision to convict | 59 | 18 | 23.37% |
| Changed the charges against the accused when pronouncing the verdict | 75 | 02 | 2.6% |
| Added new offense when issuing the verdict | 76 | 01 | 1.3% |

| REPORT OF ADHOC REPRESENTATIVE LAWYER | |
|---|---|
| 1 | **Factors that significantly impact the pursuit of justice:** Suspects or the accused requested adjournments for responding and/or hearings, citing insufficient time to secure a free defense lawyer. Additionally, the defense lawyers lacked adequate time to study the cases.<br>- In 85% of cases, investigating judges summoned the clients without issuing invitation to the lawyers to attend.<br>- In 70% of cases, investigating judges and/or trial judges delayed summoning[16] the clients and issuing invitation to the lawyers to accompany them and attend the hearing.<br>- In 70% of cases, the administrative police delayed delivering court summonses to the clients, often doing so just one day before the hearing or appearance date.<br>The judge adjourned the trial without providing prior notice to the lawyers or the clients. |
| 2 | **Obstacles preventing lawyers from studying the cases:** In 85% of human rights and land-related cases involving political issues, lawyers were not allowed to make complete copies of the cases for the following reasons: the judges or prosecutors had not yet reviewed or signed the documents, the cases were considered confidential, or they were required to seek approval from a higher authority (by requesting permission from their superior). |
| 3 | **The court's failure to notify[17]:** In more than 90% of cases, the courts (court officials, prosecution representatives, investigating judges) failed to inform the lawyers of the verdicts, including: filling a case without handling order, orders to close investigations, detention orders, orders for judicial supervision, final conclusion verdicts, and settlement verdicts. |
| 4 | **Factors influencing clients' interest in seeking justice[18]:** The disallowance of exculpatory witnesses from providing testimony, the trial judge's refusal to summon or failure to summon exculpatory witnesses as requested by the lawyers during the investigation and trial stages. It can seriously impact the accused's right to self-defense if the court relies solely on the records of a judicial police officer. |

[16] Refer to Article 466 of the Criminal Procedure Code for criminal cases if the cases are handled by the prosecutor and the trial judge, and to Articles 236 and 238 of the Criminal Procedure Code if the cases are handled by the investigating judge.
[17] Refer to articles 236 and 238 of the Criminal Procedure Code.
[18] Refer to Articles 110 and 118 and Article 321 of the Criminal Procedure Code

## V. Recommendations

1. The Ministry of Justice should review and take specific measures against the actions of judges and prosecution representatives that contravene the objectives of Article 208 and Article 209 of the 2007 Criminal Procedure Code, which outline the duration of pre-trial detention. According to the report, 42 out of 77 (54.54%) pre-trial detentions lasted more than six months and up to 18 months, marking an increase of 8.83% from the end of 2023 (80 cases out of a total of 175).
2. The Ministry of Justice should review and impose severe administrative penalties against judges and prosecution representatives who delay performing their duties and opening hearings. According to the report, the court (judges) still delayed hearings, with the delays varying from an hour and a half to more than three hours, compared to the time specified in the order.
3. The Ministry of Justice should review and take specific measures against the actions of judges and prosecution representatives who delay issuing invitations to lawyers and clients to attend hearings.
4. The Ministry of Justice should review and take specific measures against the actions of judges and prosecution representatives who delay issuing invitations to lawyers to accompany their clients and listen to their statements during the prosecution stage.
5. The Ministry of Justice should review and take specific measures against the actions of judges and prosecutors who fail to notify the final order, such as closing order and settlement order.
6. Judges/prosecution representatives should be mindful when using words or statements regarding the guilt or innocence of an accused person before issuing a verdict, such as advising the accused to admit guilt or instructing the plaintiff to withdraw their complaint.
7. Judges should review and consider the rights of the accused, such as those who are wearing prison uniforms or being handcuffed during hearings.
8. Judges should explain to the accused and the victims the rights to which they are entitled, such as the right to legal representation, the right to remain silent, the right not to be coerced into admitting guilt, the right to the presumption of innocence, the right to be informed of the charges, and the right to be informed of the date and place of the offense.
9. The Ministry of Justice should take specific measures to require all courts of first instance to allow the public and journalists to attend public hearings without restriction or eviction.